សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**សារលិខិត**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងឱកាសទិវាសន្តិភាពអន្តរជាតិ**
**ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧**

សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
ជនរួមជាតិជាទីស្នេហា

**ទិវាសន្តិភាពអន្តរជាតិ** ត្រូវបានប្រារព្ធទូទាំងពិភពលោកនៅថ្ងៃទី២១ ខែកញ្ញា ជារៀងរាល់ឆ្នាំ បន្ទាប់ពីមានការអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិលើកទី៥៥ នាឆ្នាំ២០០១ ដើម្បីលុបបំបាត់អំពើហិង្សា បញ្ឈប់សង្គ្រាម ជម្រុញឲ្យមានសុខសន្តិភាពក្នុងប្រទេស ក្នុងតំបន់ ក៏ដូចជាក្នុងពិភពលោកទាំងមូល។

ដោយមានការយល់ដឹងពីតម្លៃដែលពុំអាចកាត់ថ្លៃបាន និងសារៈសំខាន់នៃសន្តិភាពសម្រាប់ប្រទេសជាតិកម្ពុជាមានសេចក្តីសោមនស្សរីករាយ នាថ្ងៃទី២១ ខែកញ្ញា នេះ ចូលរួមជាមួយពិភពលោកប្រារព្ធនូវ **ទិវាសន្តិភាពអន្តរជាតិ** ដើម្បីលើកកម្ពស់ការយល់ដឹងពីអត្ថន័យនៃសន្តិភាពឲ្យកាន់តែទូលំទូលាយ ពង្រឹងសាមគ្គីភាព ឯកភាពជាតិ បន្តជម្រុញស្មារតីនិងពួតដៃគ្នាជាធ្លុងមួយថែរក្សាឲ្យបានគង់វង្សនូវសុខសន្តិភាព សម្រាប់កម្ពុជាយើង ដែលជាសេចក្តីប្រាថ្នារបស់មនុស្សគ្រប់រូប និងជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់ប្រទេសបោះជំហានបន្តទៅមុខលើវិថីអភិវឌ្ឍន៍ និងការរីកចម្រើន។

**ជនរួមជាតិជាទីស្នេហា!**

សុខសន្តិភាពរបស់ប្រទេសជាតិ និង ប្រជាជនគឺជាអាទិភាពដែលឈរលំដាប់ខ្ពស់បំផុតសម្រាប់រាជរដ្ឋាភិបាលកម្ពុជា ដែលគ្មានអ្វីមកជំនួសបានឡើយ។

សម្រាប់កម្ពុជា នេះគឺជាសន្តិភាពដែលបានមកពីការបូជាសាច់ស្រស់ឈាមស្រស់ក្នុងការតស៊ូរំដោះប្រទេសជាតិចេញពីរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលបានសម្លាប់រង្គាលប្រជាជនខ្មែរ និងបំផ្លាញគ្រប់ហេដ្ឋារចនាសម្ព័ន្ធទូទាំងប្រទេសស្ទើរសូន្យ ។ ក្រោយថ្ងៃរំដោះ ៧ មករា ឆ្នាំ ១៩៧៩យើងបានតស៊ូជំនះគ្រប់

ឧបសគ្គដើម្បីកសាងប្រទេសពីគំនរផេះផង់ ដោយបាតដៃទទេ ក្រោមការដាក់ទណ្ឌកម្ម និងការដាក់អោយឯកោពីសហគមន៍អន្តរជាតិផង និងការបន្តសង្គ្រាមឧទ្ទាមពីសំណាក់ខ្មែរក្រហមដែលនៅតែបន្តធ្វើទុក្ខបុកម្នេញប្រជាពលរដ្ឋខ្មែរក្នុងសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃយូរអង្វែង។

រហូតដល់ឆ្នាំ១៩៩៨ក្រោមនយោបាយឈ្នះ-ឈ្នះរបស់រាជរដ្ឋាភិបាល នៅពេលដែលយើងសម្រេចបាននូវការបំផ្លាញចោលទាំងស្រុងនូវអង្គការចាត់តាំងរបស់ខ្មែរក្រហម ទើបកម្ពុជាស្គាល់រសជាតិពិតនូវអ្វីដែលហៅថា សន្តិភាពពិតប្រាកដ និងការគ្រប់គ្រងអធិបតេយ្យពេញបរិបូរណ៍ ។

ក្រោមម្លប់នៃសន្តិភាពនេះហើយ ដែលកម្ពុជាបានចាប់ផ្តើមមានឱកាសក្នុងការអភិវឌ្ឍប្រទេស និងងើបមុខឡើងវិញបន្តិចម្តងៗនៅលើឆាកអន្តរជាតិ។ យើងមានមោទនភាពដែលកម្ពុជាមានសន្ទុះកំណើនសេដ្ឋកិច្ចខ្ពស់រហូតដល់ជាង៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ និងបន្តមានកំណើន ៧.១% ក្នុងឆ្នាំនេះ និងឆ្នាំបន្ទាប់។ ជាតុផ្សំនៃសន្តិភាព អត្រាកំណើនសេដ្ឋកិច្ចខ្ពស់ រួមផ្សំនឹងការដាក់ចេញនូវគោលនយោបាយអភិវឌ្ឍន៍ជាតិដ៏ត្រឹមត្រូវក្រោមយុទ្ធសាស្ត្រចតុកោណ បានធ្វើអោយអត្រានៃភាពក្រីក្ររបស់ប្រជាជនខ្មែរថយចុះពី ៥៣.២% ក្នុងឆ្នាំ២០០៤ មកនៅត្រឹម ១៣.៥% ក្នុងឆ្នាំ២០១៤ និងបានលើកស្ទួយកម្រិតជីវភាពរបស់ប្រជាជនទាំងមូលអោយកាន់តែប្រសើរឡើង។ នៅឆ្នាំ ២០១៦ កម្ពុជាក៏បានងើបផុតចេញពីឋានៈជាប្រទេសដែលមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។

ទន្ទឹមនឹងការរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ច កម្ពុជាតែងតែបានខិតខំលើកកំពស់លទ្ធិប្រជាធិបតេយ្យប្រកបដោយសន្តិភាព យោងលើគោលការណ៍គោរពនីតិរដ្ឋដូចដែលបានស្តែងចេញតាមរយៈការបោះឆ្នោតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាបន្តបន្ទាប់កន្លងមក ជាពិសេសគឺការបោះឆ្នោតឃុំ-សង្កាត់កាលពីខែ មិថុនា កន្លងទៅថ្មីៗនេះដែលបានប្រព្រឹត្តទៅដោយរលូន គ្មានហិង្សា មានការចូលរួមដោយសេរី យុត្តិធម៌ និងមានការទទួលស្គាល់និងអបអរសាទរជាលក្ខណៈអន្តរជាតិ។ កម្ពុជាតែងតែប្រកាន់ខ្ជាប់ផងដែរនូវគោលការណ៍ជាសកលនៃការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ហើយរាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការទប់ស្កាត់រាល់សកម្មភាព ល្បិចកិច្ចកល ការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ការអុចអាល រើសអើងពូជសាសន៍ ដែលអាចបង្កហិង្សា ការបះបោរ និងបំបែកបំបាក់សាមគ្គីភាពជាតិក្រោមផ្លាកលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ដែលមានគោលបំណងបំរើផលប្រយោជន៍នយោបាយរបស់បុគ្គល ឬក្រុមមនុស្សមួយក្តាប់តូច និងបរទេសដែលចង់ផ្លាស់ប្តូររាជរដ្ឋាភិបាលស្របច្បាប់។ការរិះគន់ មួលបង្កាច់រាជរដ្ឋាភិបាលដោយឥតឈប់ឈរ ដែលធ្វើឡើងដោយលំអៀង និងមើលលើហេតុការណ៍តែមួយជ្រុង និងការបន្តទាមទារលទ្ធិប្រជាធិបតេយ្យផ្ទុយនឹងគោលការណ៍នីតិរដ្ឋ ពិតជាមិនមែននាំមកនូវសុខលទ្ធិប្រជាធិតេយ្យប្រកបដោយសន្តិភាពនោះទេ ប៉ុន្តែផ្ទុយទៅវិញវាអាចបំផ្លិចបំផ្លាញសន្តិភាពដែលកម្ពុជាទើបតែបានស្គាល់មិនដល់២ទសវត្សរ៍ផងនោះអោយរលាយសូន្យ ដូចជាករណីប្រទេសមួយចំនួនដែលធ្លាក់ចូលក្នុងភ្លើងសង្គ្រាមដោយសារបដិវត្តន៍ពណ៌ ដែលជ្រកក្រោមស្លាកលទ្ធិប្រជាធិបតេយ្យ។

ហេតុដូច្នេះហើយ រាជរដ្ឋាភិបាលមានការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការការពារសន្តិភាពនេះ ព្រោះថាសន្តិភាពដែលយើងបានមកនេះគឺជាសេចក្តីសុខរួមសម្រាប់យើងទាំងអស់គ្នា។ អតីតកាលរបស់យើងក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ យើងខ្លោចផ្សាខ្លាំងណាស់ យើងរងទុក្ខវេទនារួមគ្នា ដូច្នេះ សម្រាប់អនាគតខាងមុខកម្ពុជាត្រូវរក្សាសន្តិភាពអោយខាងតែបាន ទោះដោយតម្លៃណាក៏ដោយ ។

**ជនរួមជាតិជាទីស្នេហា**

អតីតកាលដែលពោរពេញដោយទុក្ខវេទនា មិនត្រឹមតែជម្រុញឲ្យរាជរដ្ឋាភិបាលធានាបាននូវសន្តិភាពក្នុងប្រទេសប៉ុណ្ណោះទេ តែថែមទាំងចូលរួមជាមួយបណ្តារដ្ឋផ្សេងៗ និងសហគមន៍អន្តរជាតិជួយស្វែងរកសន្តិភាពដល់ប្រទេសដែលកំពុងមានជម្លោះ ក្រោមក្របខណ្ឌនៃកិច្ចប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ។ ចាប់ផ្តើមពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ន កម្ពុជាបានបញ្ជូនកងកម្លាំងជាង ៤៧០០ នាក់ រួមទាំងស្ត្រី និងបុរសបំរើការក្នុងបេសកកម្មរក្សាសន្តិភាព ដូចជាការបោសសំអាតមីន កម្ទេចគ្រាប់មិនទាន់ផ្ទុះ តម្រួតយោធា វិស្វកម្មនិងសំណង់ ពេទ្យ សេនាធិការ និងសង្កេតការណ៍ ទៅក្នុងប្រទេសចំនួន ០៨ រួមមាន ស៊ូដង់ ស៊ូដង់ខាងត្បូង ឆាដ អាហ្វ្រិកកណ្តាល លីប៊ី សាយព្រឹស ស៊ីរី និងម៉ាលី ។

កម្ពុជាក៏បានដើរតួនាទីក្នុងការចូលរួមធានានូវសន្តិភាព និងសន្តិសុខពិភពលោកតាមរយៈ ការចូលជាភាគីនៃសន្ធិសញ្ញា និងពិធីសារអន្តជាតិជាច្រើន ដូចជា “សន្ធិសញ្ញាស្តីពីការមិនផលិតអាវុធនុយក្លេអ៊ែរ” “អនុសញ្ញានិងពិធីសារអន្តរជាតិស្តីពីការហាមឃាត់ការផលិត ការស្តុកទុក និងការប្រើប្រាស់មីន អាវុធគីមី និងអាវុធជីវសាស្ត្រ និង “អនុសញ្ញាស្តីពីការប្រយុទ្ធប្រឆាំងនឹងភេរវកម្ម”។ល។

ក្នុងស្មារតីថែរក្សាសន្តិភាពរបស់ជាតិយើង ទូលព្រះបង្គំ សូមអំពាវនាវដល់ជនរួមជាតិទាំងអស់ ចូលរួមក្នុងការថែរក្សាសន្តិភាព ពង្រឹងឯកភាពជាតិ អនុវត្តវប្បធម៌សន្ទនា គោរពច្បាប់ ដោះស្រាយបញ្ហាដោយសន្តិវិធី និងទប់ស្កាត់រាល់ឧបាយកល និងការប៉ុនប៉ងតាមគ្រប់រូបភាពដែលមានគោលបំណងធ្វើឲ្យ ប្រទេសជាតិធ្លាក់ក្នុងសភាពវឹកវរ និងអស្ថិរភាព។

ជាចុងក្រោយ ខ្ញុំសូមប្រសិទ្ធពរជូនជនរួមជាតិជាទីស្នេហា សូមបានប្រកបដោយពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៧

**ហ៊ុន សែន**